# ក្របខ័ណ្ឌសមត្ថភាពកម្លាំងពលកម្ម NDIS៖ សៀវភៅមគ្គុទេសក៍ជម្រើសអាជីព

Khmer | ភាសាខ្មែរ

ក្របខ័ណ្ឌសមត្ថភាពកម្លាំងពលកម្ម NDIS (ក្របខ័ណ្ឌ) ពណ៌នាអំពីអាកប្បកិរិយា ជំនាញ និងចំណេះដឹងដែលត្រូវបានរំពឹងទុកពីបុគ្គលិកទាំងអស់ដែលបានទទួលមូលនិធិនៅក្រោម NDIS។ វាផ្តល់នូវឧទាហរណ៍ច្បាស់លាស់ និងជាក់ស្តែងមួយចំនួន ហើយបង្កើតជាភាសារួមអំពី 'អ្វីដែលមើលទៅល្អ' សម្រាប់អ្នកចូលរួមទាំងឡាយដែលកំពុងទទួលសេវា និងការគាំទ្រពី NDIS។ សៀវភៅមគ្គុទេសក៍នេះគាំទ្រក្របខ័ណ្ឌសមត្ថភាពកម្លាំងពលកម្ម។

សៀវភៅមគ្គុទេសក៍ជម្រើសអាជីពអាចជួយបុគ្គលិកក្នុងការស្វែងរកការងារ និងឱកាសការងារនានានៅក្នុងវិស័យពិការភាព និងវិស័យដែលពាក់ព័ន្ធ។ វាអាចជួយមនុស្សដែលចាប់អារម្មណ៍ក្នុងវិស័យនេះឱ្យយល់ដឹងពីរបៀបដែលពួកគេអាចប្រើប្រាស់ និងអភិវឌ្ឍជំនាញ សមត្ថភាព និងចំណាប់អារម្មណ៍សម្រាប់អាជីពផ្នែកគាំទ្រជនពិការ។

*មានវិធីជាច្រើនដើម្បីពង្រីក ឬធ្វើឱ្យល្អូតលាស់ដល់អាជីពផ្នែកគាំទ្ររបស់អ្នក។ ការយល់ដឹងអំពីជម្រើសអ្វីខ្លះ និងអ្វីខ្លះដែលនឹងរំពឹងទុកពីអ្នក គឺជាគន្លឹះក្នុងការសម្រេចចិត្តដ៏សំខាន់។*

## អ្វីខ្លះដែលនឹងរំពឹងទុក

សៀវភៅមគ្គុទេសក៍ស្វែងយល់ពីលំនាំផ្លូវបួនខុសៗគ្នាទៅកាន់ឱកាសការងារ៖

- **ស្វែងរក** ភាពចម្រុះបន្ថែមទៀតនៅក្នុងប្រភេទនៃការងារគាំទ្រ
- **ផ្តោត** លើប្រភេទនៃការគាំទ្រជាក់លាក់មួយដើម្បីធ្វើឯកទេសកម្ម
- **គាំទ្រ** បរិយាបន្ន និងលទ្ធភាពប្រើប្រាស់សម្រាប់ជនពិការ
- **ផ្លាស់តួនាទី** ទៅក្នុងតួនាទីមើលការខុសត្រូវ ឬតួនាទីជួរមុខផ្សេងទៀត។

សៀវភៅមគ្គុទេសក៍ផ្តល់នូវយោបល់ និងអ្វីខ្លះដែលត្រូវពិចារណាដើម្បីជួយអ្នកក្នុងការសម្រេចចិត្តថាតើនេះជាទិសដៅដែលអ្នកចង់ធ្វើឬអត់។ តួនាទីត្រូវបានពណ៌នា ហើយធនធាន និងគន្លឹះនានាសម្រាប់ជំហានបន្ទាប់ត្រូវបានផ្តល់ជូន។ សៀវភៅមគ្គុទេសក៍នេះផ្តល់ដំបូន្មានទូទៅ ហើយអ្នកគួរតែពិចារណាពីកាលៈទេសៈ និងកត្តាផ្ទាល់ខ្លួនរបស់អ្នកមុនពេលសម្រេចចិត្តលើការផ្លាស់ប្តូរអាជីពបន្ទាប់របស់អ្នក។

អ្នកអាចត្រឡប់ទៅវិញ និងជ្រើសរើសជម្រើសផ្សេងទៀតបានគ្រប់ពេល។ អ្នកក៏អាចទាញយក និងបោះពុម្ពច្បាប់ចម្លងនៃសៀវភៅមគ្គុទេសក៍នេះដើម្បីប្រើប្រាស់ក្រៅបណ្តាញបានផងដែរ។

## សៀវភៅមគ្គុទេសក៍នៅក្នុងការអនុវត្ត៖

Bill គឺជាបុគ្គលិកគាំទ្រដែលបំពេញតួនាទីគាំទ្រទូទៅជាច្រើន។ គាត់ចូលចិត្តធ្វើការជាមួយជនពិការ។ គាត់ចង់បង្កើតអាជីពក្នុងវិស័យនេះ និងស្វែងយល់បន្ថែមអំពីជម្រើសនានាដូចជា ជំនាញក្នុងការធ្វើការជាមួយប្រភេទនៃការគាំទ្រជាក់លាក់ ឬការផ្លាស់ប្តូរទៅតួនាទីគ្រប់គ្រងជួរមុខ។ គាត់មិនប្រាកដពីចំណុចខ្លាំងរបស់គាត់ប្រៀបជាមួយនឹងជម្រើស និងជំហាននានាដែលគាត់ត្រូវធ្វើដើម្បីឈានដល់អាជីពរបស់គាត់យ៉ាងណានោះទេ។

Bill ប្រើប្រាស់ **សៀវភៅមគ្គុទេសក៍ជម្រើសអាជីព** ដើម្បីស្វែងយល់ពីសមត្ថភាពដែលនឹងត្រូវការ និងទទួលបានគន្លឹះមួយចំនួនអំពីអ្វីដែលត្រូវធ្វើបន្ទាប់ទៀត ដើម្បីស្វែងរកជម្រើសអាជីពខុសៗគ្នា។ គាត់សម្រេចចិត្តបន្តចំណាប់អារម្មណ៍របស់គាត់ក្នុងការធ្វើការជាមួយជនពិការចិត្តសាស្ត្រសង្គម ហើយប្រើប្រាស់ព័ត៌មាននៅក្នុងសៀវភៅមគ្គុទេសក៍ដើម្បីរៀបចំផែនការជំហានបន្ទាប់របស់គាត់។

Bill ក៏ប្រើ **ក្របខ័ណ្ឌសមត្ថភាពកម្លាំងពលកម្ម** ផងដែរដើម្បីជួយគាត់ឱ្យយល់ដឹងអំពីសមត្ថភាពបន្ថែមដែលរំពឹងទុកសម្រាប់ការគាំទ្រដល់ជនពិការចិត្តសាស្ត្រសង្គម។

## ការចូលប្រើប្រាស់ និងការប្រើប្រាស់សៀវភៅមគ្គុទេសក៍

សៀវភៅមគ្គុទេសក៍ជម្រើសអាជីពត្រូវបានប្រើប្រាស់យ៉ាងល្អបំផុតតាមអនឡាញ ទោះបីជាយ៉ាងណាក្តី អ្នកអាចទាញយកកំណែដែលអាចប្រើបាននៅក្រៅបណ្តាញដែលផ្តល់ព័ត៌មានស្រដៀងគ្នា។

**ចូលប្រើសៀវភៅមគ្គុទេសក៍៖** សៀវភៅមគ្គុទេសក៍ជម្រើសអាជីព | សមត្ថភាពកម្លាំងពលកម្ម NDIS ( ndiscommission.gov.au )

សម្រាប់ព័ត៌មានបន្ថែមអំពីក្របខ័ណ្ឌ ឬការអនុវត្តរបស់សៀវភៅមគ្គុទ្ទេសក៍នេះ សូមចូលមើលគេហទំព័រ៖ https://workforcecapability.ndiscommission.gov.au/។

**ទំនាក់ទំនង៖** contactcentre@ndiscommission.gov.au ឬ 1800 035 554។